ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៦
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ។
សាលក្រមលេខ: ១៨ ( ង )
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ:នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលជំនុំជម្រះក្តីនៃសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ដោយមានសមាសភាពដូចខាងក្រោម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:១២៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted]ផា ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ទា ទីកន្លែងកំណើតភូមិ[redacted]ខេត្តតាកែវ និងទីលំនៅមុនពេលគេចខ្លួននៅភូមិ[redacted]ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ផាន (រស់) ម្តាយឈ្មោះ [redacted] សុត (រស់) ប្រពន្ធឈ្មោះ [redacted] ណៃ (រស់) មានកូនចំនួន ០២នាក់ ទោសពីមុន គ្មាន។ (គេចខ្លួន) ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ។

ជាប់ចោទពីបទ: ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ។ ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ២៦៥ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។



Scanned with CamScanner

-បានឃើញដីកាដំណោះស្រាយលេខ:៣០៦៩/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ:៣០៩ ដចត ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៤ និង ០០នាទី នៅចំណុចភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ មានករណីប៉ុនប៉ងឃាតកម្មមួយបានកើតឡើង បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ផា ភេទប្រុស អាយុ ៤៣ឆ្នាំ បានធ្វើសកម្មភាពយកទឹកអាស៊ីតជះ និងយកកាំបិតតាំងតោកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ២៥ឆ្នាំ បណ្តាលអោយរបួសរបកផ្ទៃមុខ ដាច់កដៃខាងឆ្វេង ត្រូវក្បាលពីក្រោយ និងដាច់ចន្លោះម្រាមដៃខាងស្តាំ ពេលនោះជនរងគ្រោះបានធ្វើពុតជាស្លាប់ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] ផា បានរត់គេចខ្លួនបាត់។ ក្រោយពេលកើតហេតុ បងប្អូនជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចនិងបានកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ផា បានអវត្តមាននាពេលសវនាការដោយពុំដឹងមូលហេតុ តែមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ:៨៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តតាកែវ។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា បានឆ្លើយថា៖ពីពេលមុនមកខ្លួន និងឈ្មោះ [redacted] ផា ធ្លាប់មានទំនាក់ទំនងរយ:ពេលប្រហែល ០៦ឆ្នាំមកហើយ ហើយការទំនាក់ទំនងគ្នានេះ ប្រពន្ធរបស់គាត់ក៏បានដឹងដែរ។ នៅថ្ងៃកើតហេតុទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងប្រហែល៤ទៀបភ្លឺ ឈ្មោះ [redacted] ផា បានតេទូរស័ព្ទតាមរយ:បងស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីសៀង ឲ្យខ្លួនទៅយកកាតគ្រីម៉ូតូនៅម្តុំភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ដោយគាត់និយាយថាប្រញ៉ាប់ទៅប៉ៃលិនភ្លាមនោះខ្លួនក៏បានជិះម៉ូតូទៅតែម្នាក់ឯង។ ពេលជួបភ្លាមគាត់បានសួរខ្លួនថាហ្អែងបានទាក់ទងជាមួយប្អូនអាភាប៉ុន្មានឆ្នាំហើយ ខ្លួនតបថាអត់មានទេ ឈ្មោះ ផា បានតបថាមិនបាច់កុហកទេអញដឹងអស់ហើយ ភ្លាមនោះឈ្មោះ [redacted] ផា បានយកដបទឹកអាស៊ីតពីកែបម៉ូតូមកជះលើមុខខ្លួនតែម្តង ខ្លួនរត់បាន២-៣ ជំហ៊ានងងឹតមុខដួល ឈ្មោះនេះបានយកកាំបិតកាប់មកលើរូបខ្លួនជាច្រើនកាំបិតត្រូវក្បាល ត្រូវដៃស្តាំរងត្រូវរបួសដៃ និងដៃឆ្វេងត្រូវដាច់ត្រឹមកដៃ ពេលនោះខ្លួនធ្វើពុតជាស្លាប់ទើបឈ្មោះ [redacted] ផា ឡើងជិះម៉ូតូចេញបាត់ទៅ។ ក្រោយពេលកើតហេតុខ្លួន បានតេទូរស័ព្ទប្រាប់បងស្រីឈ្មោះ [redacted] ស្រីសៀង ថាមកយកខ្លួនផង ខ្លួនត្រូវបានគេកាប់ហើយ។ ក្រោយពេលកើតហេតុខ្លួនត្រូវបានបងប្អូនយកទៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ បានរយ:ពេលមួយអាទិត្យ និងបន្តទៅព្យាបាលនៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ដោយមានការឧបត្ថមពីអង្គការសហប្រតិបត្តិការ រហូតមកដល់សព្វថ្ងៃនេះ នៅតែមិនទាន់បានជាសះស្បើយនៅឡើយទេ។

ក្នុងរឿងនេះខ្លួនប្ដឹងសុំទាមទារសំណងជំងឺចិត្តចំនួន ៤០ម៉ឺនដុល្លារអាមេរិក និងថ្លៃព្យាបាលដែលជាសំណងនៃការខូចខាតចំនួន ៤០ម៉ឺនដុល្លារអាមេរិក ព្រមទាំងសុំឲ្យតុលាការផ្ដន្ទាទោសជននេះតាមច្បាប់។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ស្រីសៀង បានឆ្លើយថា៖នៅថ្ងៃកើតហេតុវេលាម៉ោង ៤ទៀបភ្លឺ នៅពេលដែលខ្លួនឡើងទៅជួយបោចមាន់ពូលក់ ស្រាប់តែឈ្មោះ[redacted]ផា គេមកខ្លួនថា: ឲ្យប្រាប់ឈ្មោះ[redacted]ចិន្តា អោយទៅយកកាតគ្រីម៉ូតូនៅភូមិព្រៃតាប៉ាក ដោយគាត់ប្រញ៉ាប់ទៅប៉ៃលិន។ ខ្លួនបានប្រាប់ ចិន្តា តាមការណាត់របស់ឈ្មោះ [redacted] ផា។ ពេលប្អូនទៅបាត់មួយសន្ទុះ វាក៏បានតេទូរស័ព្ទប្រាប់ថា បងមកយកខ្ញុំផងគេកាប់ខ្ញុំងាប់ហើយ។ ហើយភ្លាមៗនោះខ្ញុំនិងបងប្អូនក៏នាំគ្នាទៅដល់កន្លែងកើតហេតុឃើញប្អូនស្រីដេកក្នុងថ្លុកឈាម ហើយវាបានប្រាប់ថាឈ្មោះ [redacted] ផា ជាអ្នកកាប់វា។ បន្ទាប់មកក៏នាំគ្នាដឹកប្អូនយកទៅមន្ទីរពេទ្យតែម្ដង។ ខ្លួនធ្លាប់តែបានដឹងថាឈ្មោះ [redacted] ផា និងប្អូនស្រីខ្លួនឈ្មោះ [redacted] ចិន្តា មានទំនាក់ទំនងជាមួយគ្នារយៈពេលប្រហែលបីឆ្នាំមកហើយ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] គឹមហេង បានឆ្លើយថា៖នៅពេលកើតហេតុខ្លួនមិនបានឃើញទេ លុះក្រោយពេលកើតហេតុទើបខ្លួនបានដឹង និងឮ បងស្រីខ្លួនបានប្រាប់ថាឈ្មោះ [redacted] ផា ជាអ្នកកាប់គាត់។

-តាមចម្លើយសាក្សីឈ្មោះ [redacted] តឿ បានឆ្លើយថា៖នៅថ្ងៃកើតហេតុវេលាម៉ោង ៣ទៀបភ្លឺ ក្មួយខ្លួនឈ្មោះ [redacted]ចិន្តា និងឈ្មោះ [redacted] ស្រីសៀង បានមកជួយបោចមាន់ ទា ខ្លួនដើម្បីលក់។ លុះដល់ម៉ោង៤ ទៀបភ្លឺឈ្មោះ [redacted] ចិន្តា បានជិះម៉ូតូចេញបាត់ទៅមួយសន្ទុះ ក្រោយមកស្រាប់តែឈ្មោះ [redacted] ស្រីសៀង ប្រាប់ខ្លួនថា ចិន្តា ត្រូវបានឈ្មោះ [redacted]ផា កាប់ងាប់ហើយ។ ភ្លាមនោះខ្លួន និងឈ្មោះ [redacted] ស្រីសៀង ព្រមទាំងបងប្អូននាំគ្នាជិះម៉ូតូទៅដល់កន្លែងកើតហេតុ ខ្លួនបញ្ចាំងភ្លើងពិលមើល ស្រាប់តែឃើញក្មួយចិន្តា ដេកក្នុងថ្លុកឈាម ឃើញដៃម្ខាងដាច់ត្រឹមកដៃនៅក្បែរខ្លួន កំប៉ុងទឹកអាស៊ីត ស្បែកជើង និងម៉ូតូបញ្ឈរចោលនៅទីនោះ។ បន្ទាប់មកនាំគ្នាយកជនរងគ្រោះទៅមន្ទីរពេទ្យ។ពេលក្មួយដឹងខ្លួនម្ដងៗវាបានប្រាប់ថាឈ្មោះ [redacted] ផា ជាអ្នកកាប់វា។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សុខា បានឆ្លើយថា៖នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ស្រីសៀង បានប្រាប់ខ្លួនថាគេកាប់ ចិន្តា នៅភូមិព្រះម្លប់ ងាប់ហើយ។ បន្ទាប់ពីបានដឹងដំណឹងនេះរួចហើយខ្លួន និងបងស្រីឈ្មោះ [redacted] ស្រីសៀង ព្រមទាំងបងប្អូនជិះម៉ូតូនាំគ្នាទៅដល់កន្លែងកើតហេតុ ស្រាប់តែឃើញចិន្តា ដេកក្នុងថ្លុកឈាម រួចក៏នាំគ្នាដឹកគាត់ទៅមន្ទីរពេទ្យ ពេលនោះគាត់បានប្រាប់ខ្លួនថាឈ្មោះ [redacted] ផា ជាអ្នកកាប់គាត់។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ បានធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការនេះថា៖ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងឯកសារជាភស្តុតាងនានានៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ផា ពិតជាបានកាប់ទៅលើកូនក្ដីខ្លួនឈ្មោះ [redacted] ចិន្តា បណ្ដាលអោយរងរបួសធ្ងន់ធ្ងរ រហូតដល់ពិការភាពអស់មួយជីវិត។ ដូច្នេះសំណូមពរសុំអោយតុលាការផន្ទាទោសជនជាប់ចោទរូបនេះកំរិតអតិបរិមានៃទោសអោយបានតឹងរឹងបំផុត ហើយសំណងជំងឺចិត្ត និងថ្លៃព្យាបាលសុំអោយសំរេចតាមការទាមទាររបស់កូនក្ដីខ្លួនផង។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ តាមការស្ដាប់ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងឯកសារជាភស្តុតាងនានានៅក្នុងសំណុំរឿង មានភាពស៊ីសង្វាក់



Scanned with CamScanner

ទៅនឹងអង្គហេតុបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ផា ពិតជាបានប្រព្រឹត្តអំពើដ៏សាហាវកាប់ទៅលើជនរងគ្រោះ ថែមទាំងយកទឹកអាស៊ីតជះទៅលើមុខជនរងគ្រោះបណ្តាលអោយរងរបួសយ៉ាងធ្ងន់ធ្ងរដែលចូលជាបទល្មើស ប៉ុនប៉ងឃាតកម្ម ត្រូវផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ អំពើនេះធ្វើអោយប៉ះពាល់សណ្តាប់ធ្នាប់សង្គម ជាពិសេសប៉ះពាល់ដល់រូបរាងកាយបុគ្គល ដែលច្បាប់បានការពារ។

-សំណូមពរ៖

១.សុំឱ្យផ្តន្ទាទោសជនជាប់ចោទរូបនេះអោយបានតឹងរឹងបំផុតព្រោះការប្រព្រឹត្តរបស់ជនជាប់ចោទមានលក្ខណៈសាហាវព្រៃផ្សៃខ្លាំងណាស់។

២.ស្នើសុំចេញដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយបច្ចុប្បន្នជនជាប់ចោទបានគេចខ្លួនតាំងពីថ្ងៃកើតហេតុមកម្លេះ។

៣.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ឆ្លងតាមអង្គសវនាការនេះឃើញថាពិតជាមានអង្គហេតុដែលបង្កឡើងដោយកូនក្តីខ្លួនឈ្មោះ គុប ផា ប្រាកដមែន តែការបង្ករឿងហេតុនេះ គឺមិនមែនតែកូនក្តីខ្លួនម្នាក់ឯងទេ គឺជនរងគ្រោះក៏បានចូលរួមផងដែរ ព្រោះថាកូនក្តីខ្លួន និងជនរងគ្រោះធ្លាប់មានទំនាក់ទំនងគ្នាជាយូរឆ្នាំមកហើយ ក្រោយមកជនរងគ្រោះសុំបែកទើបធ្វើអោយកូនក្តីខ្លួនមានកំហឹង ទើបឈានចូលដល់ការប្រព្រឹត្តបទល្មើសបែបនេះ។ សំណូមពរសុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

-ក្រោយពីបានស្តាប់អំណានដីកាបង្គាប់អោយចាប់ខ្លួនជនត្រូវចោទឈ្មោះ គុប ផា

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះដែលត្រូវជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិអោយជនរងគ្រោះដែលត្រូវជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទ

-ក្រោយពីក្រុមប្រឹក្សាជំនុំជម្រះបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

**សាលាដំបូងខេត្តតាកែវ**

**យល់ឃើញថា៖**

១-ដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ផា តាមដីកាលេខៈ៨៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ មានលក្ខណៈត្រឹមត្រូវគ្រប់កិច្ចស៊ើបសួរនៃនីតិវិធីនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះលើកយកសំណុំរឿងព្រហ្មទណ្ឌលេខៈ១២៦ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ មកពិចារណាដើម្បីធ្វើការជំនុំជម្រះតាមច្បាប់។



Scanned with CamScanner

២-តាមចម្លើយរបស់ជនរងគ្រោះ ដែលត្រូវជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្ដា បានឆ្លើយនាពេលសវនាការថ្ងៃនេះថា៖ពីពេលមុនមកខ្លួន និងឈ្មោះ[redacted] ផា ធ្លាប់មានទំនាក់ទំនងរយៈពេលប្រហែល ០៦ឆ្នាំមកហើយ ហើយការទំនាក់ទំនងគ្នានេះ ប្រពន្ធរបស់គាត់ក៏បានដឹងដែរ។ នៅថ្ងៃកើតហេតុទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងប្រហែល៤ទៀបភ្លឺ ឈ្មោះ [redacted] ផា បានតេទូរស័ព្ទតាមរយៈបងស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីសៀង ឱ្យខ្លួនទៅយកកាតគ្រីម៉ូតូនៅម្ដុំភូមិព្រះម្លប់ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ ដោយគាត់និយាយថាប្រញ៉ាប់ទៅប៉ៃលិនភ្លាមនោះខ្លួនក៏បានជិះម៉ូតូទៅតែម្នាក់ឯង។ ពេលជួបភ្លាមគាត់បានសួរខ្លួនថាហ្វេងបានទាក់ទងជាមួយប្អូនអាភាប៉ុន្មានឆ្នាំហើយ ខ្លួនតបថាអត់មានទេ ឈ្មោះ ផា បានតបថាមិនបាច់កុហកទេអញដឹងអស់ហើយ ភ្លាមនោះឈ្មោះ [redacted] ផា បានយកដបទឹកអាស៊ីតពីកែបម៉ូតូមកជះលើមុខខ្លួនតែម្ដង ខ្លួនរត់បាន២-៣ជំហ៊ានងងឹតមុខដួល ឈ្មោះនេះបានយកកាំបិតមកកាប់លើរូបខ្លួនជាច្រើនកាំបិតត្រូវក្បាល ត្រូវដៃស្ដាំរងត្រូវរបួសដៃ និងដៃឆ្វេងត្រូវដាច់ត្រឹមកដៃ ពេលនោះខ្លួនធ្វើពុតជាស្លាប់ទើបឈ្មោះ [redacted] ផា ឡើងជិះម៉ូតូចេញបាត់ទៅ។ ក្រោយពេលកើតហេតុខ្លួន បានតេទូរស័ព្ទប្រាប់បងស្រីឈ្មោះ[redacted]ស្រីសៀង ថាមកយកខ្លួនផង ខ្លួនត្រូវបានគេកាប់ហើយ។ ក្រោយពេលកើតហេតុខ្លួនត្រូវបានបងប្អូនយកទៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃបានរយៈពេលមួយអាទិត្យ និងបន្តទៅព្យាបាលនៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ដោយមានការឧបត្ថមពីអង្គការសហប្រតិបត្តិការរហូតមកដល់សព្វថ្ងៃនេះ នៅតែមិនទាន់បានជាសះស្បើយនៅឡើយទេ។ចម្លើយនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណា។

៣-តាមចម្លើយសាក្សីឈ្មោះ [redacted] ស្រីសៀង ,ឈ្មោះ [redacted] គីមហេង ,ឈ្មោះ [redacted] តឿ និងឈ្មោះ [redacted] សុខា បានឆ្លើយមានលក្ខណៈស៊ីសង្វាក់គ្នានាពេលសវនាការថ្ងៃនេះថា៖នៅថ្ងៃកើតហេតុវេលាម៉ោង៣ទៀបភ្លឺ ក្មួយខ្លួនឈ្មោះ [redacted]ចិន្ដា និងឈ្មោះ [redacted] ស្រីសៀង បានមកជួយបោចមាន់ ទា ខ្លួនដើម្បីលក់។ លុះដល់ម៉ោង៤ ទៀបភ្លឺឈ្មោះ[redacted]ចិន្ដា បានជិះម៉ូតូចេញបាត់ទៅមួយសន្ទុះ ក្រោយមកស្រាប់តែឈ្មោះ [redacted] ស្រីសៀង ប្រាប់ខ្លួនថា ចិន្ដា ត្រូវបានឈ្មោះ[redacted] ផា កាប់ងាប់ហើយ។ ភ្លាមនោះខ្លួន និងឈ្មោះ [redacted]ស្រីសៀង ព្រមទាំងបងប្អូននាំគ្នាជិះម៉ូតូទៅដល់កន្លែងកើតហេតុ ខ្លួនបញ្ចាំងភ្លើងពិលមើល ស្រាប់តែឃើញក្មួយចិន្ដាដេកក្នុងថ្លុកឈាម ឃើញដៃម្ខាងដាច់ត្រឹមកដៃនៅក្បែរខ្លួន កំប៉ុងទឹកអាស៊ីត ស្បែកជើង និងម៉ូតូបញ្ឈរចោលនៅទីនោះ។ បន្ទាប់មកនាំគ្នាយកជនរងគ្រោះទៅមន្ទីរពេទ្យ។ពេលក្មួយដឹងខ្លួនម្ដងៗវាបានប្រាប់ថាឈ្មោះ [redacted] ផា ជាអ្នកកាប់វា។ចម្លើយនេះក៏គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណា។

៤-សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់លោកតំណាងអយ្យការ នាពេលសវនាការថ្ងៃនេះថា៖ ផ្អែកតាមការសួរដេញដោលនាពេលសវនាការនេះ តាមការស្ដាប់ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងឯកសារជាភស្តុតាងនានានៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ផា ពិតជាបានប្រព្រឹត្តអំពើដ៏សាហាវកាប់ទៅលើជនរងគ្រោះ ថែមទាំងយកទឹកអាស៊ីតជះទៅលើមុខជនរងគ្រោះបណ្ដាលអោយរងរបួសយ៉ាងធ្ងន់ធ្ងរដែលចូលជាបទល្មើស ប៉ុនប៉ងឃាតកម្ម ត្រូវផ្ដន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ អំពើនេះធ្វើអោយប៉ះពាល់សណ្ដាប់ធ្នាប់សង្គម ជាពិសេសប៉ះពាល់ដល់រូបរាងកាយបុគ្គល ដែលច្បាប់បានការពារ។



Scanned with CamScanner

៥-លោក [redacted] មេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ បានធ្វើសេចក្តីសន្និដ្ឋានថា៖ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងឯកសារជាភស្តុតាងនានានៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ផា ពិតជាបានកាប់នៅលើកូនក្តីខ្លួនឈ្មោះ [redacted] ចិន្តា បណ្តាលអោយរងរបួសធ្ងន់ធ្ងរ រហូតដល់ពិការភាពអស់មួយជីវិត។ ដូច្នេះសំណូមពរសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទរូបនេះកំរិតអតិបរិមានៃទោសអោយបានតឹងរឹងបំផុត ហើយសំណងជំងឺចិត្ត និងថ្លៃព្យាបាលសុំអោយសំរេចតាមការប្តឹងសុំទាមទាររបស់កូនក្តីខ្លួនផង។

៦-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ឆ្លងតាមអង្គសវនាការនេះឃើញថាពិតជាមានអង្គហេតុដែលបង្កឡើងដោយកូនក្តីខ្លួនឈ្មោះ គុប ផា ប្រាកដមែន តែការបង្ករឿងហេតុនេះ គឺមិនមែនតែកូនក្តីខ្លួនម្នាក់ឯងទេ គឺជនរងគ្រោះក៏បានចូលរួមផងដែរ ព្រោះថាកូនក្តីខ្លួន និងជនរងគ្រោះធ្លាប់មានទំនាក់ទំនងគ្នាជាយូរឆ្នាំមកហើយ ក្រោយមកជនរងគ្រោះសុំបែកទើបធ្វើឲ្យកូនក្តីខ្លួនមានកំហឹងទើបឈានចូលការប្រព្រឹត្តបទល្មើសបែបនេះ។ សំណូមពរសុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

៧-ផ្អែកតាមចម្លើយជនរងគ្រោះដែលត្រូវជាដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សីនានា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ សេចក្តីសន្និដ្ឋានការពាររបស់លោកមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះដែលត្រូវជាដើមដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានការពាររបស់លោកមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ មានភាពស៊ីសង្វាក់ទៅនឹងកំណត់ហេតុឯកសារ ដែលជាភស្តុតាងនានាមាននៅក្នុងសំណុំរឿងអាចកំណត់បានថាពិតជាកើតមាននូវអំពើ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ផា ភេទប្រុស អាយុ ៤៣ឆ្នាំ បានយកទឹកអាស៊ីត និងកាំបិតតាំងតោជាឧបករណ៍ធ្វើសកម្មភាពជះលើមុខ និងកាប់ត្រូវចំក្បាល ដៃខាងស្តាំ ដៃខាងឆ្វេងដាច់កដៃជនរងគ្រោះឈ្មោះ [redacted] ចិន្តា ប្រាកដមែន។

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ផា មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទៈប៉ុនប៉ងឃាតកម្ម ដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងបញ្ញត្តិមាត្រា ១៩៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៩-ជនជាប់ចោទជានីតិជនមានស្មារតីគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស ដោយប្រើប្រាស់នូវទឹកអាស៊ីត និងកាំបិតតាំងតោ ជះទៅលើមុខ និងកាប់ជនរងគ្រោះត្រូវចំក្បាល ដៃខាងស្តាំ និងដៃឆ្វេងដាច់ត្រឹមកដៃ ដែលអំពើនេះធ្វើឲ្យប៉ះពាល់របៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម និងអាយុជីវិតរបស់រូបវន្តបុគ្គលយ៉ាងធ្ងន់ធ្ងរ។

១០-ដីកាបង្គាប់អោយចាប់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ផា តាមដីកាលេខៈ៨៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តតាកែវ ដែលបានចេញចាប់ខ្លួនរួចហើយនោះ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចចេញដីកាបញ្ជប់ឲ្យចាប់ខ្លួនចាប់ពីពេលនេះតទៅ។

១១-ដើម្បីធានានូវការអនុវត្តទោសក្នុងពន្ធនាគារ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ផា ដោយអនុលោមតាមបញ្ញត្តិមាត្រា ៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីពេលនេះតទៅ។

១២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា និងជាជនរងគ្រោះផងនោះ ខ្លួនសុំទាមទារនូវសំណងនៃការខូចខាតដែលជាថ្លៃព្យាបាលនូវប្រាក់ចំនួន ៤០ម៉ឺនដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៤០ម៉ឺនដុល្លារអាមេរិក ពី



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] ផា ។ ការទាមទារនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះលើកយកមកពិចារណា និងសម្រេចតាមភាពជាក់ស្តែង។

១៣-វត្ថុចាប់យកមាន៖ស្បែកជើងផ្ទាត់ចំនួន ០២គូ ពណ៌ខៀវ លេខ១០ ចំនួន ០១គូ និងស្បែកជើងពណ៌ផ្កាឈូក ចំនួន ០១គូ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចរឹបអូស និងបំផ្លាញចោល។

១៤-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ផា ភេទប្រុស អាយុ ៤៣ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ពីបទ:ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ផា ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល១៤ (ដប់បួន)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានពីបទ:ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិព្រះម្លប់ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

២-ចេញដីកាបញ្ឈប់អោយចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ផា តាមដីកាបង្គាប់អោយចាប់ខ្លួនលេខ:៨៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ចាប់ពីពេលនេះតទៅ។

៣-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ផា ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) យកមកអនុវត្តទោសពន្ធនាគារ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីពេលនេះតទៅ។

៤-វត្ថុចាប់យកមាន៖ស្បែកជើងផ្ទាត់ចំនួន ០២គូ ពណ៌ខៀវ លេខ១០ ចំនួន ០១គូ និងស្បែកជើងពណ៌ផ្កាឈូក ចំនួន ០១គូ ត្រូវរឹបអូស និងបំផ្លាញចោល។

៥-បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted] ផា សងសំណងនៃការខូចខាតដែលជាថ្លៃព្យាបាល និងប្រាក់ជម្ងឺចិត្តសរុបចំនួន៨០០.០០០.០០០៛០០ (ប្រាំបីរយលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ផា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា ទុកសិទ្ធិប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

តាកែវ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner